វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
លេខ: ១៥៩ប្រក/ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ ២០០២

# ប្រកាស ស្តីពីការរៀបចំលេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីខេត្តឧត្តរមានជ័យ និងសមាសភាពគណៈកម្មការសុរិយោដីស្រុកក្នុងខេត្តឧត្តរមានជ័យ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ០២/នស/ ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ១៩៩៩ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួង រៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រម លេខនស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសអោយប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី
- បានឃើញអនុក្រឹត្យលេខ ៣៤៧ អនក្រ.តត.ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០២ ស្តីពីការតែងតាំងសមាសភាពគណៈកម្មការសុរិយោដីថ្នាក់ជាតិ
- យោងប្រកាសលេខ០៧៧ ប្រកចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០២ ស្តីពីការតែងតាំងសមាសភាពគណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុង
- តាមសំណើររបស់គណៈកម្មការសុរិយោដីខេត្តឧត្តរមានជ័យ

## សំរេច

ប្រការ ១ : ត្រូវបានបង្កើតលេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដី ខេត្ត ឧត្តរមានជ័យ ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១- លោក ស៊ឹម ប៊ុនឈឿន | អនុប្រធានមន្ទីរ ដនសស.ខេត្តឧត្តរមានជ័យ ទទួលបន្ទុកការងារសុរិយោដីនិងភូមិសាស្ត្រ | ជាប្រធាន |
| ២- លោក គីម តារិន | អនុប្រធានការិយាល័យសុរិយោដីនិងភូមិសាស្ត្រមន្ទីរដនសស.ខេត្តឧត្តរមានជ័យ | ជាអនុប្រធាន |
| ៣- លោក អ៊ឹម អន | ប្រធានការិយាល័យរដ្ឋបាលនៃមន្ទីរដនសស.ខេត្តឧត្តរមានជ័យ | ជាមន្ត្រីជំនួយការ |
| ៤- លោក សុខ សារិន | មន្ត្រី នៃមន្ទីរដនសស.ខេតឧត្តរមានជ័យ | ជាមន្ត្រីជំនួយការ |

ប្រការ ២ : ត្រូវបានរៀបចំសមាសភាពគណៈកម្មការសុរិយោដីស្រុកក្នុងខេត្តឧត្តរមានជ័យ ដូចខាងក្រោម :

ក. គណៈកម្មការសុរិយោដីស្រុកសំរោង :

| | | |
|---|---|---|
| ១- លោក ម៉ៅញ សុវុធ | ប្រធានការិ.ដនសភស្រុកសំរោង | ជាប្រធាន |
| ២- លោក ផាត់ រាត្រី | អនុប្រធាន ការិយាល័យ ស្រុកសំរោង | ជាសមាជិក |

Downloaded from http://www.khmerlaws.com

វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

ខ. គណៈកម្មការសុរិយោដីស្រុកចុងកាល់ :

១- លោក ក្តត ហាក់ ប្រធានការិ.ជនសភស្រុក ចុងកាល់ ជាប្រធាន

ប្រការ ៣ : លេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីក្រុង គណៈកម្មការសុរិយោដីខណ្ឌទាំងអស់ក្នុងក្រុងប៉ៃលិន មានបេសកកម្មអនុវត្តនូវភារកិច្ចរបស់ខ្លួនដូចមានចែងក្នុងអនុក្រឹត្យ លេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី ។

ប្រការ ៤: នាយកខុទ្ទកាល័យ ប្រធានលេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ ប្រធានគណៈកម្មការសុរិយោដីក្រុងប៉ៃលិន ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្តឧត្តរមានជ័យ អស់លោក ដូចមានរាយនាមក្នុងប្រការ ១ និងប្រការ ២ ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

Downloaded from http://www.khmerlaws.com